# ភាគទី១

តើអ្នកជឿលើរឿងអបិយជំនឿ មន្តអាគម ខ្មោចព្រាយបិសាចដែរឬទេ? បើជឿ តើជឿកម្រិតណាដែរ? ចុះអ្នកធ្លាប់ឮអ្វីខ្លះទាក់ទងនឹងរឿងអស់នេះ?

នៅក្នុងតំណាលមុនៗដូចជា អណ្ដូងខាងលិច គាថាបុរាណ និងអាគមបរព្រៃ យើងបានដឹងពីរឿងពិតគួរឱ្យភ្ញាក់ផ្អើលមួយចំនួន។ ចំណែកពេលនេះ ខ្ញុំមានរឿងពិតមួយថ្មីរបស់ សែមដែលនាំមិត្តពីរនាក់ទៀតមកយាមផ្ទះបងជាមួយគ្នាក្នុងសង្កាត់ស្ងប់ស្ងាត់មួយ។

--------

ផ្ទះនេះពិតជាធំជាងកាលដែលខ្ញុំបានគិត។

តាមពិតទៅ ដោយសារខ្ញុំពេញចិត្តនឹងបន្ទប់ជួលសព្វថ្ងៃដែលមានមាននិស្សិតរៀននៅសាកលជាមួយគ្នាស្នាក់នៅច្រើន ម្ល៉ោះហើយអត់បានមកនៅទីនេះតាមដែលសែមនិងសុផារីនបបួលទេ។

មិត្តភក្តិខ្ញុំសែម គេទទួលបន្ទុកយាមកាមផ្ទះនេះជំនួសឱ្យបងជីទួតមួយរបស់គេម្នាក់សញ្ជាតិអាមេរិក ទើបតែបានទិញអចលនទ្រព្យមួយនេះក្នុងតម្លៃច្រើនគួរសមដែរ។

នេះគឺជាប្រភេទផ្ទះវីឡាថ្ម សាងសង់ឡើងក្នុងសម័យសង្គមរាស្ត្រនិយម បានន័យថាមិនជាចាស់ខ្លាំងដូចបណ្ដាសំណង់សល់ពីជំនាន់បារាំងទេ។ ទាំងក្រោមនិងជាន់លើ មានលក្ខណៈពិសេស ដោយសារមានបទដ្ឋានខ្យល់ចេញចូលល្អ និងព័ទ្ធជុំវិញទៅដោយសួនច្បារ ដើមរុក្ខាម្លប់ត្រឈៃ។

ទីនេះក៏មានសល់អាងទឹកចាស់មួយនៅចំពីមុខផង។ មើលទៅបរិយាកាសដូចនេះស័ក្តិសមសម្រាប់ការអង្គុយរៀនពេលយប់ និងជប់លៀងណាស់ បានជាកន្លងមកឧស្សាហ៍ឮសែមនិងសុផារីនមានពិធីជប់លៀង តែខ្ញុំឃ្លាងមិនបានមកនឹងគេ។

ខ្ញុំឈ្មោះកក្កដា ជាមិត្តម្នាក់ក្នុងចំណោមមិត្តជិតដិតបំផុតរបស់សុផារីន។

ចំណែកឯសែមនេះក៏បានស្គាល់តែតាមរយៈសុផារីនដែរ។ ឮមកថា គេជាគ្រូបង្វឹកអត្តពលកម្មក្រៅម៉ោង ក៏ជានិស្សិតកំពុងសិក្សាបន្តផ្នែកសង្គមវិទ្យានៅភ្នំពេញដែរ។

ក្រោយពួកគេរើមកនៅទីនេះបានប្រមាណជាងមួយអាទិត្យ សុផារីនបានសរសេរឆែតមកឡកលើយខ្ញុំថា គេឃើញនារីម្នាក់ញញឹមរកខ្លួននៅខាងត្បូងផ្ទះនេះ។ ក្រោយមកសុផារីនបាន

វិលទៅស្រុកវិញប្រថុបញ៉ុច ទុកតែPost It តូចមួយបិទប្រាប់សែម និងមិនតបសារឬខលរបស់មិត្តឡើយ ថែមទាំងមិនបាននិយាយថា មានហេតុភេទអ្វីទាំងអស់។ ទោះយ៉ាងណាគ្មានអ្នកណាដឹងរឿងនេះឡើយ រហូតដល់មានមិត្តភក្តិត្រូវបានគ្រូប្រើឱ្យទៅរកសុផារីនដល់ផ្ទះនៅស្រុកកំណើត ទើបដឹងការពិតថា អ្នកផ្ទះរីនមិនដែលឃើញរីនវិលមកវិញឡើយ។

តើគេទៅណា?

ខ្ញុំងាកទៅសែមដែលកំពុងឈរក្បែរបង្អួចមើលទូរសព្ទ។

«ផ្ទះធំដល់ហើយ មកដេកតែពីរនាក់វាមែនឬម៉េច?»

ខ្ញុំពោលសួរបែបនេះ ធ្វើឱ្យសែមងើបមុខមកសម្លឹងខ្ញុំដោយស្រងូត ហើយទើបឆ្លើយ៖

«មានអាយុទ្ធនៅសាលាច្បាប់និងពួកម៉ាកវា២នាក់ទៀត តែពួកនោះយប់ៗជ្រៅបានមក!»

«ហើយអត់មានអ្នកណាដឹងដំណឹងសុផារីនទាំងអស់? បីអ្នកហ្នឹងណ៎ា មានខលសួរអត់?!»

សែមមិនឆ្លើយនឹងសំណួរថ្មីនេះទេ បែរជាញាក់ស្មាជំនួសឱ្យពាក្យថា«គ្មានអ្នកណាដឹងឡើយ»។

ឥឡូវនេះសូម្បីតែដាក់បណ្ដឹងទៅសមត្ថកិច្ច អាជ្ញាធរមូលដ្ឋានក៏យើងបានធ្វើរួចរាល់ពីរបីថ្ងៃហើយដែរ។

ការគ្មានដំណឹងរបស់សុផារីននៅតែជាប្រស្នា ដែលបង្ខំខ្ញុំចាំបាច់ត្រូវមកកាន់ទីកន្លែងនេះនៅថ្ងៃនេះ ក្រែងអាចរកឃើញអ្វីម្យ៉ាង ឬអាចសាកសួរបានដំណឹងបន្ថែម។

ទោះយ៉ាងណាបរិស្ថានជុំវិញនេះស្ងាត់ឱ្យសូន្យ ដូចជាពិបាកនឹងកំណត់ទិសដៅស្វែងរកព័ត៌មានពីអ្នកជិតខាងបន្តិច។

ភ្លាមនោះខ្ញុំនឹកឃើញដល់សារឆ្លងឆ្លើយចាស់ៗ ដូចជាមានពេលមួយដែលសុផារីនបាននិយាយអំពីមនុស្សស្រីម្នាក់នៅផ្ទះជាប់ខាង។

«ផ្ទះឈើនេះ មានគេនៅអត់?»

ខ្ញុំសួរទៅកាន់សែមដោយដើរមកបង្អួចខាងត្បូងអើតសម្លឹងមើលទៅផ្ទះឈើចាស់មួយធំនិងស៊ុបទ្រុប។ ផ្ទះនេះនៅក្បែរខាងជាប់ព្រំរបងតែទំហំធំជាងផ្ទះថ្មខាងណេះ។ បរិវេណខាងក្រោមផ្ទះមានដីទំនេរ ឈើត្រៃឈៃ ម្លប់គ្របសឹងពិបាកមើលឃើញអ្វីៗខាងក្នុងបានច្បាស់។

មិនយូរប៉ុន្មានខ្ញុំសង្កេតឃើញផ្ទះនេះមានជណ្តើរខាងមុខមួយ បែរទៅទិសខាងជើង។ សែមដើរមកអើតក្បែរខ្ញុំដែរ ហើយនិយាយខ្សឹបៗ៖

«ដូចមានមនុស្សនៅតើ! គ្នាមិនសូវបានចាប់អារម្មណ៍ដែរ»

ខ្ញុំសម្លឹងហួសទៅរបងខាងមុខផ្ទះរបស់គេ ឃើញមានតូបលក់បាយមួយ។

សែមនិយាយបន្ថែមតិចៗ៖

«ដូចធ្លាប់ឃើញមានលក់បាយ តែឯងឯណោះចេញចូលពីព្រលឹមបាត់ៗមិនសូវដឹងទេ! មិនសូវចាប់អារម្មណ៍!»

«ធ្លាប់ឮផាវីននិយាយថា វាញ៉ែស្រីម្នាក់នៅផ្ទះក្បែរខាងអត់?» ខ្ញុំសួរខ្សឹបខ្សៀវទាំងងាកមើលមុខគូសន្ទនាម្នាក់នេះ ឃើញថាសែមធ្វើមុខមិងមាំង គ្មានពាក្យតប ស្មើនឹង«មិនដឹង»។ គេញាក់ស្មារលាស់ដៃដូចពួកបរទេស។

អាការៈរបស់សែមគឺមិនបានដឹងរឿងអ្វីទាំងអស់។

«មនុស្សបាត់ខ្លួនទាំងមូលអ្ហ៎ា!»

ខ្ញុំបន្ទោសតិចៗដោយដើរចូលក្នុងវិញ។ មិនឱ្យខ្ញុំបន្ទោសយ៉ាងម៉េចវាជាអ្នកបបួលមិត្តខ្ញុំមកស្នាក់ជួយមើលផ្ទះបងវា លុះដល់មានរឿងសួរអីក៏មិនដឹង?

សែមឮភាពទោមនស្សរបស់ខ្ញុំក៏ដើរតាមមកតវ៉ាពីក្រោយខ្នងខ្ញុំ៖

«មានអ្នកណាដឹងអ្ហ៎ា បើវាមិននិយាយស្ទីស្រាប់តែបាត់ខ្លួនទៅ! ម្នាក់ៗសុទ្ធតែរវល់ កប់ៗយប់ដូចគ្នា! ណាមួយសុផាវីនវាមានសង្សារច្រើនណាស់ កក្កដាឯងក៏ដឹងដែរ វាអាចនឹងទៅពួនសង្សារចាស់ ឱបសង្សារថ្មីផ្អែមល្ហែមដូចទឹកឃ្មុំនៅឯណាផងមិនដឹង គេម៉េចនឹងប្រាប់យើង!»

ខ្ញុំឱនមករើរុះមើលឯកសារ សៀវភៅនានាលើតុមួយនៅក្បែរក្បាលគ្រែរបស់សុផាវីនទាំងមាត់តបតវិញ៖

«ប៉ុន្តែវាធម្មតាទៅណាតែងខលទៅលេងអ្នកផ្ទះនៅខេត្ត សុផាវីនទោះបីជាព្រាននារី ប៉ុន្តែវាស្រឡាញ់ម្តាយវាណាស់ ខ្ញុំស្គាល់វាយូរហើយ វាមិនដែលបាត់គ្មានដំណឹងរបៀបនេះទេ! ចោលសាលា ចោលផ្ទះ!»

សែមលែង មាត់។

ពីកញ្ចក់តូចមួយប៉ុនសន្លឹកក្រដាសA4ដែលបញ្ឈរលើតុសុផាវីន ខ្ញុំអាចលបមើលទៅកិរិយាសែម ឃើញគេបែរខ្នងរៀបចំសម្លៀកបំពាក់ដែលបត់ជាគំនរលើគ្រែគេ ដាក់ទៅក្នុងកាបូបស្បែកធំមួយ ដែលធម្មតាខ្ញុំឃើញសែមស្ពាយកាបូបនេះរាល់ពេលធ្វើដំណើរទៅបេសកកម្មខេត្ត។

«សែមឯងលេងនៅហ្នឹងទៀតហើយ?!»

ខ្ញុំសួរដោយងាកក្រោយសម្លឹងគេ។ សែមឆ្លើយតបមិនងើបមុខទេ៖

«មានរឿងអ៊ីចឹង ចង់លំហែចិត្តបន្តិចសិន ចាំអាវីនមកវិញសិនចាំគិតទៀតថានៅបន្តឬក៏អត់! ពិបាកដែរផ្ទះនេះធំពេក!»

សម្ដីសែមនិយាយធ្វើដូចគេច្បាស់ថាសុផាវីននឹងវិលមកវិញ ហើយការបាត់ខ្លួនទៅនេះដូចជារឿងធម្មតាៗសម្រាប់គេ។

ខ្ញុំងើបមុខសម្លឹងពិតាន។ ចម្លាក់ប្រាង្គប្រសាទអង្គរវត្តលើនោះទំនងជាសល់តាំងពីសង្គមចាស់ហើយត្រូវបានជូតលាងជ្រះស្អាត ខ្ញុំគិតថាពេលដែលពួកគេនាំគ្នាចូលមករស់នៅទីនេះសែមនិងសុផាវីន បានរៀបចំសម្អាតកន្លែងនេះសមរម្យណាស់។ គ្រាន់តែចម្លាក់អស់នេះប្រសិនមានគេចូលមកលបគាស់កាយលក់បន្ត ក៏សឹងមានតម្លៃថ្លៃ ម្ល៉ោះហើយវាមិនសមទេដែលថា ផ្ទះនេះគួរទុកចោលគ្មានអ្នករក្សាការពារ។

វិលមកគ្រែរបស់គេនេះវិញ ប្រដាប់ប្រដារបស់សុផាវីន នៅសេសសល់ក្លួយខ្មើយគ្រប់យ៉ាងហាក់បីដូចជាមិនបានដឹងខ្លួនថានឹងត្រូវទៅពួននៅកន្លែងណាបាត់ស្រមោលដូច្នេះទេ។

«ឆ្ងល់ដែរ វាទៅណាវា?!»

សំណួរខ្លីរបស់សែមនេះ ញ៉ាំងខ្ញុំឱ្យបែរទៅរកគេ។ គេកំពុងតែរូតបិទបញ្ចប់កាបូបស្បែក។

«វាអាចមានរឿងទេ?!»

ខ្ញុំសួរសែម ឯគេឆ្លើយមកដោយបែរខ្នងដាក់ខ្ញុំ៖

«ពិបាកសន្យាបន្តិចរឿងសុផាវីន! វាឧស្សាហ៍មានរឿងជាមួយនឹងកូនស្រីគេណាស់! ឪពុកម្ដាយគេរករឿងញយហើយ! គេអាចគុំគួន ធ្វើអីចំពោះវាដឹង?!»

«កុំនិយាយរឿងមិនល្អ!» ខ្ញុំតបទាំងមិនសប្បាយចិត្ត។ សែមនៅស្ងៀមបង្អង់បន្តិចមុនពេលឆ្លើយតបវិញដោយច្បូតមុខធុញៈ

«ល្អអីទៀត? បើឯងមករុះរើពេញផ្ទះនេះហើយសួរនាំគ្នាដូចជាប៉ូលិសហើយហ្នឹង!»

ខ្ញុំនៅស្ងៀមជាសញ្ញាដឹងកំហុស។ បន្ទាប់មកសែមបោះសំណួរមកខ្លីទៀតៈ

«នៅហ្នឹង ឬចុះទៅដែរ?!»

សំណួររបស់សែមដូចជាបង្ខំខ្ញុំឱ្យចាកចេញពីកន្លែងដែលខ្ញុំមិនទាន់បានរុកឃើញអ្វីមួយតាមចិត្តប៉ងនៅឡើយផងនេះ។ តែខ្ញុំមានហេតុផលអីនៅក្រាញបើម្ចាស់ផ្ទះគេមិនចង់នៅបន្តទៅហើយ?

«ទៅដែរ!»

ខ្ញុំឆ្លើយខ្លីស្របកន្ទុយភ្នែកក្រឡេកទៅឃើញអ្វីមួយ លៀនចេញពីលើស្លាបព្រិលចាស់ចុងជើងគ្រែសុផារីន។

សែមចុះចេញទៅក្រោមដោយមិនមាត់មិនកទេខ្ញុំក៏បានឱកាសដើរទៅរករបស់នោះទាញយកមកពិនិត្យ។

សៀវភៅនេះ ដូចជាធ្លាប់ឃើញ?

សុផារីនចូលចិត្តសរសេរកំណត់ហេតុ។ គេចង់ធ្វើអ្នកនិពន្ធហើយតែងតែមានបទពិសោធស្នេហាជាមួយមនុស្សស្រីជាច្រើនសរសេរទុកក្នុងកំណត់ហេតុនានាជាបទពិសោធជីវិតយុវវ័យរបស់គេ។

មិនដឹងថា គេបានសរសេររឿងម្នាក់ស្រីផ្ទះជាប់ខាងដែលគេអះអាងថាស្អាតគួរឱ្យចាប់អារម្មណ៍ហ្នឹងដែរឬអត់?

ខ្ញុំឆ្លៀតបើកអានខ្វាកក៏ឃើញថាជាសំណេររបស់វាពិតមែន។

មិនចាំបាច់គិតច្រើន ខ្ញុំដាក់វាភ្លុចទៅក្នុងសាក់កាដូ ហើយរូតបិទមុនពេលរត់ចុះទៅក្រោមតាមពីក្រោយឈ្មោះសែម។

យប់នោះនៅផ្ទះជួលម្នាក់ឯង ខ្ញុំចាប់ផ្ដើមបើកសៀវភៅរបស់សម្លាញ់មកអាន។ ចម្លែកត្រង់ថា ហេតុអ្វីតាំងពីទំព័រដំបូងមកគឺសុផារីនបាននិយាយអំពីផ្ទះមួយនេះ?

ខាងក្រោមជាកំណត់ហេតុរបស់សុផារីន៖

----------------------

ខ្ញុំបានរើមកនៅផ្ទះរបស់បងប្រុសជីទួតមួយរបស់សែមព្រឹកមិញនេះ ទើបតែបោសជ្រះសម្អាតរួច។ ដ្បិតតែផ្ទះនេះមើលពីក្រៅចាស់បន្តិចតែគ្រប់យ៉ាងខាងក្នុងនៅល្អទាំងអស់។ ខ្ញុំនិងសែមស្នាក់នៅជាន់លើបន្ទប់ខាងកើត ពួកម៉ាក់បីនាក់ទៀតរបស់គេឮថាគេងនៅបន្ទប់ធំ។

ខ្ញុំយល់ថា ការស្នាក់នៅកន្លែងនេះស័ក្តិសមណាស់សម្រាប់មនុស្សចូលចិត្តសរសេរដូចខ្ញុំ ចំណែកអ្នកហាត់យកសាច់ដុំដូចសែមក៏មានកន្លែងរត់រាល់ព្រឹកៗឡើង មិនពិបាកខ្លាចឆ្កែអ្នកស្រុកប្រដេញតាម ដូចកាលនៅបន្ទប់ជួលទេ។

ពិសេសដោយសារខ្ញុំ មិត្តពីរបីនាក់ទៀតបានរួមគ្នាបង្កើតនូវសមាគមនិស្សិត ដើម្បីលើកកម្ពស់ការអាននិងការសរសេរ ហើយតែងតែចង់ឱ្យមានការជួបជុំគ្នាជាទ្រង់ទ្រាយតូចនិងធំជាមួយអ្នកនិពន្ធក្មេងៗនៅក្នុងសាលាយើងជាប្រចាំ ដូច្នេះហើយខ្ញុំគិតថាទីនេះមានលក្ខខណ្ឌល្អច្រើនសម្រាប់ការងារពួកយើង។

«បន្ទប់ទឹកប្រើរៀងខ្លួនទៅវ៉ើយ!»

សែមស្រែកមកពីក្រោម។

ខ្ញុំដឹងថាសែមចង់ថាឱ្យខ្ញុំ ព្រោះខ្ញុំធ្លាប់នៅបន្ទប់ជួលចូលជាមួយវាហើយមិនដែលបានជួយលាងបន្ទប់ទឹកទេ ងប់ងល់តែរឿងចេញក្រៅដើរញ៉ែស្រី ហើយបកមកវិញយប់អាធ្រាត្រអង្គុយសរសេររឿងលេង។

ចិត្តខ្ញុំទទួលស្គាល់ថាខ្ញុំ ផ្ទះនេះនៅតែធំពេកណាស់ សម្រាប់យុវវ័យ៥នាក់ដែលរវល់ការងារនិងការសិក្សា។ យើងមិនសូវមានពេលនៅ រហូតយប់ៗទើបវិលមកគេង។ ប៉ុន្តែក៏មិនពិបាកអ្វីនៅក្នុងការបោសសម្អាតច្រើនដែរ ព្រោះគ្មានក្មេងពង្រាយ។

ពេលមកខាងមុខរវ៉េងជាពិនិត្យសួនទាំងមូលដោយមើលពីលើនេះទៅ ម្តុំនេះសមណាស់ជាសង្កាត់ដ៏ស្ងាត់ជ្រងំ ទំនងធ្លាប់ជាតំបន់ដែលពួកអ្នកមានធំៗ កុងសី មន្ត្រី ប្រមូលផ្តុំគ្នារស់នៅកាលពីសង្គមចាស់។

ពេលនេះសល់ទុកមកនូវបរិវេណដីវីឡាចាស់ៗ ធំៗ ជ្រៅសន្លឹមៗខុសពីសំណង់សម័យថ្មី។ ខ្ញុំយល់ថា បងជីទួតមួយរបស់សែម ទំនងជានឹងបានចំណេញកប់ក្តោងមិនខានក្នុងការទិញផ្ទះដែលគេទុកចោលមួយនេះទុកលក់ចេញវិញនៅ ថ្ងៃក្រោយប្រាកដជាបានតម្លៃខ្ពស់ ។

មិនទាន់បានអីផងស្រាប់តែនៅបង្អួចខាងត្បូងរំលងពីកន្លែងខ្ញុំឈរដោយកូនបន្ទប់តូចមួយ ខ្ញុំឃើញនារីម្នាក់បង្ហាញខ្លួនជាមួយនឹងសក់វែងអន្លាយហិចហើរចុះឡើងតាមសន្ទឹកខ្យល់ត្រសៀក មើលមួយក្រឡេកសឹងច្រឡំថានាងញញឹមមករកខ្ញុំ។

និស្ស័យជាមួយស្រីស្អាត គឺជានិស្ស័យរបស់ខ្ញុំ។

ដោយមិនមាត់មិនក និងដៀងទៅឃើញសែមកំពុងបោសសម្អាតសួនខាងក្រោម ចំណែកម និងយុទ្ធ ជានិស្សិតនៅសាលាច្បាប់និងមិត្ត២នាក់ទៀតរបស់ពួកគេសម្អាត បន្ទប់គេងរាងខ្លួនខ្លះរើរូសផ្ទាំងគំនូរលាងជូតសំអាតព្យួរដាក់តាំងលើជញ្ជាំង។

ខ្ញុំយកឱកាសនេះរំសៀកខ្លួនភ្លែត សំដៅទៅកាន់កូនបន្ទប់នៅចុងគេនោះទីដែលអាចមើលទៅស្រីស្អាតរឹតតែកៀកឡើយ។

បន្ទប់នេះទំនងដូចជាកូនបន្ទប់ដែលម្ចាស់ផ្ទះពីមុន សាងឡើងរបៀបជាបណ្ណាល័យទុកសម្រាប់អានសៀវភៅព្រោះឃើញនៅសល់ទូប្រអប់ច្រើនខ្ពស់ដល់ពិតាន បើនឹងតំកល់សៀវភៅមិនតិចជាងពាន់ក្បាលនោះទេ។

ដោយទ្វារនិងបង្អួចបន្ទប់នេះចំហស្រាប់ បានជាមុននេះខ្ញុំអាចក្រឡេកឃើញស្រីស្អាតជិតខាង។

ពេលនេះខ្ញុំចូលមកកាន់តែកៀក គឺថាអាចបើកផ្លូវចរចាក្បែរៗនឹងបង្អួចនាងតែម្តង។ នាងមិនបានចេញទៅណានៅឡើយមែន គឺនៅបន្តឈរអានសៀវភៅទីនោះដដែលដោយទម្លាក់សក់ទន់ល្មើយ។

វត្តមានខ្ញុំបានធ្វើឱ្យនាងងើបមុខមក។

មិនបង្អង់យូរទេខ្ញុំសើចញញឹមដាក់ស្រីស្អាតជាកិច្ចស្វាគមន៍ ធ្វើឱ្យនាងទីទើរមុនពេលញញឹមតបសុភាពរាបសារមកខ្ញុំវិញ។

មិនដឹងហេតុអ្វីបានជាបេះដូងនេះចាប់អារម្មណ៍ឃើញថា មិនធ្លាប់មានសង្សារជាមនុស្សស្រីស្អាតរមទម្យថ្នាក់នេះសោះ ពីមុនមកទោះបីជានៅសាលាខ្ញុំល្បីឈ្មោះខាងមានដៃគូរាប់មិនអស់ទៅហើយក្ដី។

នាងមិនបានហាស្ដីអ្វីឱ្យសមចិត្តប៉ងប្រាថ្នាថាបានជំពាក់វាចាគ្នាសោះ ស្រាប់តែដាក់សៀវភៅចុះ បែរខ្លួនដើរចូលទៅវិញបាត់ ទាំងមិនភ្លេចក្នុងការដៀងភ្នែកសម្លឹងខ្ញុំជាចុងក្រោយផង។ កន្ទុយភ្នែកស្រីស្អាត ដូចជាតម្រុយអ្វីមួយមកជំរុញចិត្តខ្ញុំឱ្យស្វាហាប់ឡើងវិញ។

ខ្ញុំញញឹមតាមលួចមើលនាង រហូតបាំងបាត់ក្រោយជញ្ជាំងផ្ទះឈើ ទើបដើរបកត្រលប់ចូលមកក្នុងនិងចុះត្រឹកៗទៅរកសែម ។

ខ្ញុំស្រស់ស្រាយណាស់ដាក់អ្នកផ្សេងៗទៀត ព្រមទាំងមានសន្ទុះចិត្តក្នុងការជួយធ្វើការជាមួយពួកគេបន្តដោយស្វាហាប់ខ្លាំងបំផុត។

«តស់សែម ឯងចុះទៅជួយលាងសម្អាតអាងទឹកវ៉ឺ! ដាក់ឱ្យវាថ្លាឆ្វង់វិញមើល៍គ្រាន់លោតហែលលេងបង្អួតសាច់ដុំជាមួយធម្មជាតិល្អៗម្ដុំនេះ»

ពីជាន់ខាងក្រោម សែមងើបមុខមើលមកខ្ញុំដោយងឿងឆ្ងល់។ ចំណែកខ្ញុំញញឹម ខណៈចិត្តនឹកដល់មនុស្សស្អាតក្បែរៗខាង។

សែមតាមមើលខ្ញុំដែលកាន់អំបោសនិងធុងទឹកចូលទៅរកគេ។

«ក្រែងថាមុននេះថាមិនចេះលាងអាងហ្អី?!»

គេសួរនេះ ព្រោះពីព្រឹកធ្លាប់សុំខ្ញុំចុះមកជួយសម្អាតអាងទឹកជាមួយគ្នាដែរ តែខ្ញុំបដិសេធថាសម្អាតខាងលើហត់សឹងអស់ដៃទៅហើយ។ ពេលនេះសែមមិនដឹងឡើយ ពីវត្តមានស្រីស្អាតដែលបានធ្វើឱ្យខ្ញុំប្ដូរគំនិតនិងស្រស់ស្រាយស្វាហាប់ជាងមុន។

រសៀលដដែលខ្ញុំបានចេញទៅរកទិញពូក ភួយថ្មី ខ្នើយ រើអីវ៉ាន់មកនៅទីនេះច្រើនជាងកាលពីព្រឹក ព្រោះគិតថានឹងស្នាក់នៅទីនេះរយៈពេលយូរ សឹងថារហូតដល់រៀនចប់ក៏ថាបាន រីឯបើសិនជាអាចរកបានសង្សារម្នាក់នៅក្បែរៗនេះទៀត មិនរឹតតែប្រសើរ?

កំពុងតែរៀបចំពូកនិងខ្នើយព្រមទាំងរើសៀវភៅចេញពីសាក់កាដូរៀបចំលើកូនតុក្បែរក្បាលគ្រែ ដៃមួយវាយមកភឹបលើស្មាខ្ញុំ ធ្វើខ្ញុំភ្ញាក់ក្រញាង។

«យើងធ្វើម្ហូបនៅទីនេះឬក៏យ៉ាងម៉េច បើសិនធ្វើ គិតគ្នាទិញចង្ក្រានហ្គាសមករៀបចំកន្លែងដាំបាយមួយឱ្យស្រួលបួល ចំណែកបន្ទប់ណាដែលនៅសល់យើងចាក់សោទុកទៅមិនបាច់បើកទេ»

សែមនិយាយពិគ្រោះ។ ឯខ្ញុំវិញក៏ដៀងភ្នែកសម្លឹងទៅរកកូនបន្ទប់ដែលបិទបាំងប្រឡោះ ពីមុខបង្អួចនៃស្រីស្អាតអាថ៌កំបាំង។

«នឹកឃើញកាលពីព្រឹកមិញ ដើរកាត់មុខផ្ទះដែលជាប់យើងនេះ ដូចជាមានគេលក់បាយដែរតើ!»

មិត្តគេម្នាក់ឈ្មោះយុទ្ធឆ្លើយ។

«សួរគេមើល៍ ដឹងគេលក់ទាំងបីដែរអត់? យ៉ាងម៉េចៗយើងអាចហូបហ្នឹងក៏បាន!» សែមឆ្លើយ។

«បើផ្ទះបាយមិនប្រើទេចាក់សោទុកអស់ទៅ! វាធំពេក! ដាក់ឆ្នាំងដាំទឹកមួយនៅបន្ទប់ទទួលភ្ញៀវសម្រាប់ឆុងកាហ្វេ ឆុងមីអីទៅបានហើយ!»

ខ្ញុំងក់ក្បាលសែមឡើងមកវិញជាមួយនឹងធុងទឹកកកព្រមទាំងសាប៊ូម្សៅមួយកញ្ចប់ធំ គេនិយាយខ្លីៗ៖

«យើងប្រហែលជារស់នៅទីនេះបានយូរ ដោយសារបងខ្ញុំគ្មានគម្រោងលក់ដីនេះទេ! មានគេសួរច្រើនណាស់ គេចង់ទិញយកតែដីទៅសង់ធ្វើអូតែល ប៉ុន្តែគាត់ថាចង់ទុកសម្រាប់ពេលត្រឡប់មករស់នៅខ្មែរវិញនឹងសង់ផ្ទះថ្មីនៅទីនេះ !»

«តំបន់នេះទំនងណាស់ ស្ងប់ស្ងាត់ល្អ! ប៉ុន្តែពេលយប់ៗជុំវិញនេះ ប្រហែលជាស្ងាត់ខ្លាំង កុំមកវិញយប់ៗពេក!» ម្នាក់ទៀតជាមិត្តរបស់យុទ្ធនិយាយ។ ខ្ញុំមិនទាន់ស្គាល់ឈ្មោះគ្នាអស់ផង។

ទោះយ៉ាងណា ខ្ញុំគិតក្នុងចិត្តម្នាក់ឯងថាមិនស្ងាត់ពេកទេពីព្រោះមានស្រីស្អាតម្នាក់។

ខ្ញុំដងទឹកក្តៅមួយកែវលាយកាហ្វេដើរចាកចេញពីពួកគេយឺតៗ សំដៅទៅកាន់បន្ទប់សៀវភៅដដែល។ ពេលក្រុមជាតិឈ្មុយនិងសម្លឹងទីនេះចុះឡើងៗ ខ្ញុំនិយាយប្រាប់ពួកគេ៖

«បន្ទប់សៀវភៅនេះតូចល្មមអង្គុយរៀនបាន មិនបាច់ចាក់សោទេ ទុកចែកគ្នាប្រើទៅមានតុពីរស្រាប់»

គ្មានអ្នកខាងក្រោមណាឆ្លើយទេ សែមនៅខាងលើនេះក៏មិនដឹងបាត់ទៅណាដែរមិនដឹង មិនខ្វល់ថា ពួកគេឮដែរឬអត់  ខ្ញុំហៀបតែបែរក្រោយដើរចុះទៅវិញ ស្រាប់តែសំឡេងមួយហើរមកតាមខ្យល់លាន់មកប៉ះត្រចៀក៖

«ទើបរើមកនៅឬអីបង?»

...សំឡេងស្រីស្អាត?

ប្រាកដណាស់ហើយ! ខ្ញុំគិតថា គឺជាសំឡេងនារីដែលធ្លាប់បានញញឹមស្រស់ដាក់ខ្ញុំ ថែមទាំងលេងកន្ទុយភ្នែកកាលពីជួបដំបូងផង។

ខ្ញុំបែរភ្លែតសម្លឹងឆ្ពោះទៅបង្អួចដដែល។ នៅពីទីនេះទៅ ខ្ញុំឃើញនាងច្បាស់ជាងកាលពីលើកដំបូង។ ស្នាមញញឹមរបស់នាងធ្វើដូចជាមានស្និទ្ធស្នាលស្គាល់ខ្ញុំតាំងពីពេលណាមកមិនដឹង។ នាងពាក់អាវខ្មៅ ស្ដើងឆ្លុះឃើញសាច់ហ្មត់ សក់វែងអន្លាយថែមទាំងញញឹមបន្ថែមទៀត អារម្មណ៍ខ្ញុំអរភើតនឹងឱកាស។

ប្រហែលជានារីនេះមានកម្ពស់មិនសូវខ្ពស់បាន បានជាហាក់ខំជំទាស់ជើងឱនមកនិយាយជាមួយខ្ញុំ។

ខ្ញុំតបសុភាព៖

«បាទ! ខ្ញុំមកនៅតាំងពីព្រឹក! កំពុងតែរៀបចំ!»

«អ៎ ខ្ញុំសប្បាយចិត្តណាស់! ព្រោះផ្ទះនេះស្ងាត់យូរណាស់ហើយ គ្មានអ្នកណាសោះ!»

នាងនិយាយតបស្រស់ស្រាយ។

ខ្ញុំដឹងថា ជាអ្នកជិតខាងម្ដុំនេះ នាងមិនសូវឃើញមានមនុស្សនៅច្រើនបានជាស្រីស្អាតមានភាពអផ្សុករហូតដល់ពេលនេះដាច់ចិត្តរួសរាយរាក់ទាក់ជាមួយខ្ញុំដល់ម្លឹង។

ទោះបីយ៉ាងណាក៏ដោយ ក៏នេះគឺជាសញ្ញាល្អមួយ។

ខ្ញុំញញឹមថែមទាំងលេងឫកពាជាប្រុសស្អាតដាក់នាងវិញ។

«ខ្ញុំឈ្មោះផារីន!»

«ខ្ញុំមុំបង!»

នារីក៏ឆ្លើយប្រាប់ខ្ញុំវិញភ្លាមៗជាមួយឈ្មោះដ៏ពីរោះដានមកក្នុងបេះដូងកំលោះព្រានដូចជាខ្ញុំបានភ្លាមៗ។

«ខ្ញុំឮថាផ្ទះមុំលក់បាយមែនអត់?»

«ចាំ លក់ពេលព្រឹកបង!»

«អ៊ីចឹងយើងនឹងបានជួបគ្នាញឹកញាប់ហើយ ព្រោះខ្ញុំអត់មានគម្រោងដាំបាយធ្វើម្ហូបទេ! គ្នាខ្ញុំ៥នាក់ ប្រុសទាំងអស់! ហើយបើទំនេរមកលេងផ្ទះខ្ញុំផង!»

យើងនិយាយតែប៉ុណ្ណេះតែនាងហាក់ដូចសប្បាយចិត្តណាស់។

ទោះយ៉ាងណាខ្ញុំមិនទុកឱកាសល្អនោះរំលងផុតទៅងាយឡើយ ស្អែកឡើងជាពេលដែលអ្នកផ្សេងមានរវល់ចាកចេញពីព្រលឹមទៅសាលាមុន ខ្ញុំធ្វើពុតជាដេកយឺតចេញក្រោយគេ ម្ល៉ោះហើយខ្ញុំអាចឆ្លៀតឱកាសទៅញ៉ាំបាយស្រួបនិយាយឆ្កោះផ្គងជាមួយស្រីមុំដោយមិនចែករំលែករឿងដ៏ល្អអំពីវត្តមានអ្នកក្បែរខាងពិសេសនេះដល់អ្នកណាទេ។

ដែលខកបំណងនោះ ខ្ញុំទៅអង្គុយហូបបាយក៏ឃើញតែស្ត្រីចំណាស់ម្នាក់ជាអ្នកលក់ទៅវិញ។ ពេលអង្គុយហូប  ខ្ញុំខំអើតរកមើលនាងតែមិនឃើញសោះ។

នាងប្រហែលមានការងារឬចេញទៅរៀន?

នាងគួរតែចាប់អារម្មណ៍ខ្ញុំដូចខ្ញុំចាប់អារម្មណ៍នាង ពិតជាខកបំណងបន្តិចហើយព្រឹកនេះ។

ស្ត្រីចំណាស់ដែលមានទឹកមុខស្រស់ថ្លា ហាក់មិនចាប់អារម្មណ៍អ្វីនឹងការអើតឡឹមលាក់គំនួចរបស់ខ្ញុំទេ។ បាយស្រួបនេះក៏មានអ្នកចូលមកហូបជាហូរហែ ខ្ញុំក៏ហូបធ្វើតាមធម្មតាប៉ុន្តែព្យាយាមអ្នកមើលឆ្វេងស្តាំរកមើលនារីជាទីស្រឡាញ់រហូតចាកចេញមកទាំងសោកស្តាយ។

ពេញមួយថ្ងៃនេះនៅសាលាមែនតែចិត្តខ្ញុំនៅតែនឹកឃើញដល់នាងជានិច្ច។

ពេលល្ងាចឡើងមកផ្ទះវិញ ខ្ញុំឃើញមានមាន់ខ្វៃ សាច់ជ្រូកស្ងោរ អន្សម មីឆា ផ្លែចេកស្និតដែលសែមបានទិញមកដាក់សែន។ យើងបានរៀបចំ គ្រឿងសំណែនឱ្យក្លាយមកជាគ្រឿងក្លែមសម្រាប់យប់ដំបូងដែលយើងស្នាក់នៅក្នុងផ្ទះនេះ។

ពួកខ្ញុំ៤នាក់ញ៉ាំស្រាជល់កែវយ៉ាងឆ្ងាញ់ពិសាមិនខ្វល់ខ្វាយអ្វី ដោយមានម្នាក់មិនទាន់មកគេថាមានធុរៈនៅសាលាជាមួយក្រុមការងារ។ ទីបំផុតគ្រប់គ្នាដេកលក់នៅលើកៅអី ប៉ោអ៊ីព្រម

ទាំងកៅអីបត់នៅមុខវេរ៉ង់ដានៃជាន់ទីមួយ លើកលែងតែខ្ញុំដែលមិនស្រវឹងនោះទេព្រោះខ្ញុំជាប់ស្រវឹងស្នេហ៍ទៅហើយ ។